របាយការណ៍សង្ខេប
ស្តីពី
លទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ
និងអគ្គលេខាធិការដ្ឋាន
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែឆ្នូ ឆ្នាំ២០២០

ថ្ងៃទី៣០ ខែឆ្នូ ឆ្នាំ២០២០

ដោយ ឯកឧត្តម ឈឹម ឃិនជារ៉ែត
អគ្គលេខាធិការ អ.ជ.ប.ជ.អ

មាតិកា

១. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២. សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆ្នាំ២០២០

៤. បញ្ហាប្រឈម

៥. ទិសានុបន្ទាប់

១. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការងារមន្ត្រទេសក៏ផ្ទៃក្នុង

- ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២០ បានអញ្ជើញដឹកនាំគណៈប្រតិភូអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជន នៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរពវិញ្ញាណក្ខន្ធព្រះករុណា "ព្រះបរមរតនកោដ្ឋ" នៅមណ្ឌបព្រះបរមរូប នាសួនច្បារខាងកើតវិមានឯករាជ្យ។
- ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ បានអញ្ជើញចូលរួមព្រះរាជពិធីប្រទានភ្លើងជ័យ នៅវិមានឯករាជ្យ។
- ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ បានអញ្ជើញចូលរួមព្រះរាជពិធីពន្លត់ភ្លើងជ័យ នៅវិមានឯករាជ្យ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចារមគ្គទេសក៍ផ្ទៃក្នុង (ត)

- ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ បានអញ្ជើញដឹកនាំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី ២ ឆ្នាំ២០២០ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមវីដេអូខនហ្វឺរេន។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការងារមន្ត្រទេសក៏ផ្ទៃក្នុង(ត)

- ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ បានអញ្ជើញដឹកនាំកិច្ចសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២០ នៅអាជ្ញាធរ និងតាមវីដេអូខនហ្វឺរេន

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការងារមន្ត្រីទេសកិច្ចក្នុង (ត)

- ឯកឧត្តមទេសរដ្ឋមន្ត្រី បានពិនិត្យ និងសម្រេចលើសកម្មភាពនានារបស់ អ.ជ.ប.ជ.អ។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានជួបប្រជុំពិភាក្សាការងារបច្ចេកទេសជាមួយថ្នាក់ដឹកនាំរបស់ អ.ជ.ប.ជ.អ និងបានផ្តល់អនុសាសន៍ពីនីតិវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងលើកទិសដៅផែនការសកម្មភាពរបស់ អ.ជ.ប.ជ.អ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការចារមូលនិធិសកល :

• ពីថ្ងៃទី១០ ដល់១២ ខែវិច្ឆិកា ឆ្នាំ២០២០ ពីម៉ោង៧យប់ ដល់ម៉ោង ១២អធ្រាត្រ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលមូលនិធិសកល លើកទី៤៤។

• ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ ពីម៉ោង០៦ ដល់ម៉ោង០៩:៣០នាទីយប់ បានអញ្ជើញចូលរួមប្រជុំអន្តរសម័យនៃក្រុមប្រឹក្សាភិបាលមូលនិធិសកលស្តីអំពីការរៀបចំយុទ្ធសាស្ត្រនៃមូលនិធិសកល។

ឯកឧត្តមទេសរដ្ឋមន្ត្រី

៣- សកម្មភាពផ្សេងៗ :

- ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០ អញ្ជើញជាកិត្តិយសក្នុងពិធីសម្ពោធ ភាពយន្តឯកសារប្រវត្តិសាស្ត្រ "កម្ពុជាបន្ទាត់ឆ្នាំ១៩៩៨"។

- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ បានអញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវ ចំនួន៣៨ខ្សែ នៅក្រុងសៀមរាប។

ឯកឧត្តមទេសរដ្ឋមន្ត្រី

បទអន្តរាគមន៍ក្នុងកិច្ចពិភាក្សាតុមូល

ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២០ ចាប់ពីម៉ោង២:០០ បានអញ្ជើញធ្វើបទអន្តរាគមន៍ក្នុងកិច្ចពិភាក្សាតុមូលលើប្រធានបទ "ការទាញយកប្រយោជន៍ពីរចនាសម្ព័ន្ធឆ្លើយតបនៃមេរោគអេដស៍ ដើម្បីឆ្លើយនឹងការរើសអើង និងផលប៉ះពាល់សង្គម-សេដ្ឋកិច្ចដែលប្រឈមមុខដោយប្រជាជនគន្លឹះ និងអ្នកដែលគេទុកនៅកន្លៀតក្នុងអំឡុងការឆ្លងរាលដាលសកលមេរោគកូវីដ-១៩" ដែលរៀបចំដោយកម្មវិធីរួមអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ (UNAIDS) តាមបណ្តាញវីដេអូក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចព្រះអង្គម្ចាស់ក្សត្រី សោមសាវ៉ាលី ក្រុម មឿន សុត្ថាណារីនាថា។

ឯកឧត្តមទេសរដ្ឋមន្ត្រី

- ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ ពីម៉ោង០៩ដល់ម៉ោង១០យប់ បានអញ្ជើញចូលរួមប្រជុំតាម តាមវីដេអូខនហ្វឺរេន ជាមួយមូលនិធិ Bill Gates អំពីកម្មវិធីអេដស៍ ។
- ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ពីម៉ោង០៥ ដល់ម៉ោង០៦:០០នាទីយប់

បានអញ្ជើញចូលរួមស្តាប់តាម តាមវីដេអូខនហ្វឺរេននូវការទស្សទាយអំពីកំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក សម្រាប់ឆ្នាំ 2021 ដោយបណ្ឌិត James Doti នៃសាកលវិទ្យាល័យ Chapman រដ្ឋកាលីហ្វ័រនីញ៉ា សហរដ្ឋអាមេរិក ។

ឯកឧត្តម គង់ រដ្ឋា

- ពិនិត្យ ផ្តល់យោបល់ ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ការងារផ្ទៃក្នុងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីនិរន្តភាពនៃដំណើរការផ្ទៃក្នុង អ.ជ.ប.ជ.អ។

ឯកឧត្តម ជា ផលា

១- សកម្មភាពជាក់ជូនដឹង SCN 213

ក- ការងារួម

- ធ្វើបទបង្ហាញ ស្តីពីវឌ្ឍនភាពនៃការអនុវត្តសេចក្តីជូនដំណឹងលេខ ២១៣.សជណ.សស នៅក្នុងកិច្ចប្រជុំពេញអង្គ និងស្និបាតប្រចាំឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រឃុំទ្ធនឹងជំងឺអេដស៍។
- បានផ្តល់បទសំភាសន៍ដល់វិទ្យុជាតិស្តីពីវឌ្ឍនភាពនៃការអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ សជណ.សសនៅក្នុងកិច្ចសន្ទនា "ជីវិតយើងសង្គមយើង"
- បានផ្តល់យោបល់លើផែនការប្រចាំឆ្នាំ២០២១របស់អបជអ(NAA Work Plan)

ឯកឧត្តម ទា ផល (ត)

២-សកម្មភាពលើកគម្រោងមូលនិធិសកល

ក.ការអនុវត្តគម្រោងមូលនិធិសកលបច្ចុប្បន្ន

- ចូលរួម Workshop on Sharing Experiences for the implementation of HIV and TB program under GFATM។
- ផ្តល់យោបល់លើរបាយការណ៍បឋមរបស់ក្រុមការងារ End line survey on MCPI Program។
- ដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស Quarterly Meeting on MCPI។
- ពិភាក្សាជាមួយដៃគូពាក់ព័ន្ធសំខាន់ៗលើការជ្រើរើសតំណាងKPs ជាសមាជិកនៃ CCC។

ឯកឧត្តម ង៉ា ផលា (ត)

- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីបរិយាសគាំទ្រ ច្បាប់ គោនយោបាយ និងការកិច្ចក្នុងការគាំទ្រការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។
- ចូលរួមកិច្ចប្រជុំ Follow up on finding and recommendations of External Financial Audit year 2019។
- ចុះពិនិត្យការអនុវត្តគម្រោងមូលនិធិសកលរបស់ដៃគូពាក់ព័ន្ធ៖
  - តាមស្វែងយល់អំពីការងារ Mobile Van អង្គការ MHC នៅបឹងកក់។
  - នៅគ្លីនីក Chhourk Sar ស្វែងយល់អំពីSelf-Testing and PrEp។
- សកម្មភាពដឹកនាំ និងគ្រប់គ្រងគម្រោង NAA SSI HIV Grant 2018-2020។
- បានចូលរួមកិច្ចប្រជុំ Virtual meeting ជាមួយតំណាង FONPAM/ DFONPAM១៥ខេត្តតាមរយៈការសម្របសម្រួលរបស់ HACC ។

ឯកឧត្តម ជា ផលា (ត)

- បានសំភាសន៍ជាមួយកញ្ញាពិនស្រីមុំOut Reach Workerនៃអង្គការ CWPD ដែលផ្តល់សេវាដល់ FEWs ចំនួន៣០០នាក់។
- ចូលរួមជាអធិបតីក្នុងពីធីបិទគម្រោងនៅសណ្ឋាគារកាំបូឌីយ៉ាណា។
- ចូលរួមWebinar Meeting Experts

ខ. HIV FAR

- សម្របសម្រួលការកាត់បន្ថយថវិកាតាមសំណើរបស់ NCHADS។
- បានចូលរួមផ្តល់យោបល់លើការបោះឆ្នោតជ្រើសរើសតំណាងKPs។
- Meetingលើកទី១១ លើ ប្រធានបទមួយចំនួននៃកម្មវិធីរបេងគ្រុនចាញ់ RSSH និងជាពិសេសលើ Present Progress Update & Challenges of HIV Grant។

ឯកឧត្តម ជា ផលា (ត)

៣-សកម្មភាពជាមួយដៃគូអតីតឱ្យ

ក. អង្គការ UNAIDS:

- Optimization resources use for AIDS Response in Cambodia។
- Stakeholder Meeting for Community System Strengthening ជាមួយTA។
- ជួបប្រជុំ Webinar Meeting ស្តីពីការរាយតំលៃផលប៉ះពាល់ Covid-19។
- Zoom meeting on Fast Track Cities in Battambang/ Draft 5។
- បានចូលរួមជាមួយឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រធានអ.ជ.អ.ជ.ប Optimization resources use for AIDS Response in Cambodia in the Regional meeting devoted to the World AIDS Day in Asia and the Pacific.
- ចូលរួមផ្តល់ធាតុចូលដល់ ឯកសារReview and Document Barriers to the Accessibility of Young Key Populations to HIV services

ឯកឧត្តម ជា ផលា (ត)

ខ.អង្គការ USAID

- ពិភាក្សាលើការផ្តើមដំណើរផ្លូវការនៃគម្រោង LHSS ទៅនឹង Fast Track Cities Initiative Strategic។

៤-សកម្មភាពការសិក្សា ស្តីពីការពង្រឹងសមត្ថភាព ឃុំ សង្កាត់ ក្នុងការឆ្លើយតនឹងមេរោគអេដស៍ និងជំងឺអេដស៍(ថវិកាជាតិ)

- កែសម្រួលការវិភាគទិន្នន័យ

ឯកឧត្តម ជា ផលា (ត)

៥-សកម្មភាពផ្សេងៗ

- អញ្ជើញកញ្ញារាសីតំណាង TG មកធ្វើបទបង្ហាញខ្លីក្នុងកិច្ចប្រជុំPAB។
- អញ្ជើញលោកស្រីម៉ារីយ៉ា បុគ្គលិកជាប់កិច្ចសន្យា មកធ្វើបទបង្ហាញខ្លីក្នុងកិច្ចប្រជុំ AIDS Congress។
- បានចូល Webinar Meeting for WPR Statement to the 44th Board Meeting Documents។
- ផ្តល់យោបល់ដល់ក្រុមផលិតខ្សែវីដេអូរបស់អង្គការ Epic FHI 360។
- បានចូលរួមប្រជុំ CNCDA regional webinar Meeting on NCDs and Covid-19។
- ផ្តល់យោបល់ដល់ក្រុមអ្នកស្រាវជ្រាវរបស់អង្គការ ខាណា លើគម្រោង Mobil link with KPs in Northeastern Provinces នៅ អ.ជ.ប.ជ.អ។
- បានចូលផ្តល់យោបល់លើ Suggested Key points to be included in H.E NAA Chair's interventions for Regional world AIDS Day December 2,2020។
- បានចូលរួមជាអធិបតីក្នុងពិធីផ្សព្វផ្សាយនិងផ្តល់កញ្ចប់សម្ភារៈអនាម័យ ប័ណ្ណព័ត៌មានអប់រំនិងការគាំទ្រស្បៀងអាហារដល់ KPs និងPLHIV ។

លោកជំទាវ ស៊ឹម ខេងខាំ

- បានអានរបាយការណ៍សង្ខេបរបស់អគ្គលេខាធិការដ្ឋាន ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ដែលបានផ្សព្វផ្សាយក្នុងប្រព័ន្ធតេឡេក្រាម។
- បានតាមដានជាប្រចាំនូវរាល់របាយការណ៍របស់ឯកឧត្តមអនុប្រធាន និងឯកឧត្តមអគ្គលេខាធិការ ដែលបានអនុវត្តកន្លងមក ក៏ដូចជាបានចុះទៅបំពេញបេសកកម្មតាមខេត្តនានា តាមរយៈព័ត៌មានដែលបានដាក់ក្នុងតេឡេក្រាម។
- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែតុលា ឆ្នាំ២០២០ ក្រោមអធិបតីឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- បានចូលរួមប្រជុំពិភាក្សាអំពីការងារយោសនាអប់រំប្រចាំខែតុលា និងលើកទិសដៅខែវិច្ឆិកា ឆ្នាំ ២០២០ នៅវិមានឪមករា(គ៨៥)។

លោកជំទាវ ស៊ឹម ខេចខាំ (ត)

- ចូលរួមអមដំណើរឯកឧត្តមទេសរដ្ឋមន្ត្រី អញ្ជើញដាក់ និងថ្វាយកម្រងផ្កាគោរពវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបរមរតនកោដ្ឋ នាថ្ងៃទី០៨ ខែវិច្ឆិកា នៅមណ្ឌលសួនច្បារខាងកើតវិមានឯករាជ្យ។
- ចូលរួមកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតប្រចាំឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តាមបណ្តាញវីដេអូ កម្មវិធី Blue Jeans។
- បានអនុវត្តតាមការណែនាំ និងការចាត់តាំងរបស់ឯកឧត្តមប្រធាន។
- ត្រៀមបន្តការងារផ្សេងៗដែលឯកឧត្តមប្រធាន ចាត់តាំង។

ឯកឧត្តម ស៊ឹម គឹមសៃន

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍របស់អគ្គលេខាធិការដ្ឋាន។
- បានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែតុលា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចូលរួមអមដំណើរឯកឧត្តមទេសរដ្ឋមន្ត្រី ដើម្បីចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យនា និងបន្តដំណើរអញ្ជើញទៅថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា "ព្រះបរមរតនកោដ្ឋ"
- ចូលរួមកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតប្រចាំឆ្នាំ២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តម ស៊ឹម គឹមសៃន (ត)

- ចូលរួមពិនិត្យគម្រោងផែនការសកម្មភាពរៀបចំទិវាពិភពលោក១ធ្នូ ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមផ្តល់យោបល់បច្ចេកទេសទៅលើគម្រោងផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២១។
- បានធ្វើកិច្ចប្រជុំជាមួយឯកឧត្តមហោ ប៊ុនឡេង ដើម្បីសិក្សារៀនសូត្រពីគ្នាទៅវិញទៅមកស្តីពីភាពជាអ្នកដឹកនាំ ក្នុងការបញ្ចប់ជំងឺអេដស៍នៅកម្ពុជា និងនៅលើសកលលោក។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមបន្តការងារនានាដែលចាត់តាំងដោយឯកឧត្តមប្រធាន
- ត្រៀមបន្តតាមដានការអនុវត្តផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០២០ របស់ក្រសួងធម្មការ និងសាសនា ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ឯកឧត្តម តែង គន្ធី

- បានចូលរួមកិច្ចប្រជុំរួមប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចុះពិនិត្យសកម្មភាពការងារផ្តល់សេវាដល់ក្រុមបុរសរួមភេទជាមួយបុរសខេត្តសៀមរាប។
- ចូលរួមជាអធិបតី ក្នុងកិច្ចប្រជុំគ្រូបង្គោលសំរាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ នៅអគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ។
- ចូលរួមសិក្ខាសាលារបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី រយៈពេល២ថ្ងៃ។
- ចូលរួមដាក់កំរងផ្កានៃទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា។

ឯកឧត្តម តែង គន្ធី (ត)

- ចូលរួមកិច្ចប្រជុំពេញអង្គ និងសន្និបាទប្រចាំឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចូលរួមកិច្ចពិភាក្សាតុមូល ក្រុមការងារឥស្សរជនឆ្នើម ដើម្បីចូលរួមទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ ធ្នូ ២០២០
- ចូលរួមប្រជុំគណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា

ឯកឧត្តម រស់ សីលវ៉ាត់

- ចូលរួមប្រជុំតាមវីដេអូខនហ្វឺរេន ជាមួយថ្នាក់ឧត្តមមន្ត្រីនៃប្រទេសសមាជិកមហាអនុតំបន់ទន្លេមេគង្គ នៃវេទិការប្រកួរបៀងសេដ្ឋកិច្ចនៃប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដោយពិនិត្យមើលផលប៉ះពាល់សេដ្ឋកិច្ចពីជំងឺកូវីដ១៩ និងយុទ្ធសាស្ត្រទប់ទល់។
- ចូលរួមប្រជុំតាមវីដេអូខនហ្វឺរេន ជាមួយឯកឧត្តមប្រធាន ដើម្បីរៀបចំសេចក្តីព្រាងប្រកាសរបស់មណ្ឌលតំណាងនៃតំបន់ប៉ាស៊ីភិចខាងលិចនៃមូលនិធិសកល។
- ចូលរួមសង្កេតការក្នុងកិច្ចប្រជុំតាមវីដេអូខនហ្វឺរេន នៃសមាជិកមណ្ឌលតំណាងតំបន់ប៉ាស៊ីភិចខាងលិច ដែលពិនិត្យមើលផលប៉ះពាល់នៃជំងឺកូវីដ១៩ លើការអនុវត្តគម្រោងមូលនិធិសកល។
- ចូលរួមប្រជុំថ្នាក់ដឹកនាំ ដើម្បីពិនិត្យរបាយការណ៍ការងារប្រចាំខែតុលា។

ឯកឧត្តម រស់ សីលវ៉ាត់ (ត)

- ចូលរួមកិច្ចប្រជុំតាមវីដេអូខនហ្វឺរេន ថ្នាក់រដ្ឋមន្ត្រីនៃប្រទេសមហាអនុតំបន់ទន្លេមេគង្គដោយពិនិត្យមើលយុទ្ធសាស្ត្រឆ្លើយតបនឹងជំងឺកូវីដ១៩ ក្រមខណ្ឌវិនិយោគតំបន់។
- ពិភាក្សាការងារត្រៀមរៀបចំកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ។
- ចូលរួមកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតប្រចាំឆ្នាំ២០២០ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ជួបពិភាក្សាការងារជាមួយឯកឧត្តមប្រធាន ដើម្បីបញ្ជ្រាបសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ទៅក្នុងកម្មវិធីវិនិយោគនិងផែនការអភិវឌ្ឍឃុំសង្កាត់នៅខេត្តកំពង់ស្ពឺ ពង្រឹងការបញ្ជ្រាបការងារអេដស៍តាមបណ្តាលក្រសួង អនុវត្តគម្រោងរបស់ LHSS/UNAIDS និងការចុះបញ្ជីមណ្ឌលមូលនិធិសមធម៌ដល់ក្រុមអ្នកផ្ទុកមេរោគអេដស៍។

ឯកឧត្តម រស់ សីលវ៉ាត់ (ត)

- ពិនិត្យ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើសំណើរបស់ក្រុមហ៊ុនមួយ ដើម្បីសុំលិខិតគាំទ្រ សម្រាប់ការសិក្សាស្រាវជ្រាវការព្យាបាលអ្នកជំងឺអេដស៍ដោយប្រើថ្នាំបុរាណចិន។
- ផ្តល់ធាតុចូលដល់របាយការណ៍កិច្ចប្រជុំប្រចាំខែតុលា ឆ្នាំ២០២០ ជាភាសារជាតិ និងភាសាអង់គ្លេសរបស់ខុទ្ទកាល័យ។
- ត្រៀមចូលរួមប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ក្នុងកម្រិតពាក់កណ្តាលទូលំទូលាយ។
- ធ្វើការងារជាមួយមន្ត្រីបច្ចេកទេស រៀបចំចុះតាមដានការបញ្ជ្រាបការងារអេដស៍នៅស្រុកសំរោងទង។

ឯកឧត្តម រស់ សីលវ៉ាត់ (ត)

- ធ្វើការងារជាមួយមន្ត្រីបច្ចេកទេស រៀបចំពិនិត្យមើលសកម្មភាពដែលក្រសួងសមាជិក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គួរធ្វើក្នុងការចូលរួមជាមួយយើងឆ្លើយតបនឹងមេរោគអេដស៍។
- ធ្វើការងារជាមួយឯកឧត្តមអនុប្រធាន ទា ផលា លើការងារជំនួយបច្ចេកទេសរបស់អង្គការយូអិនអេដស៍ ពិសេសការសម្ភាសរបស់ទីប្រឹក្សាបច្ចេកទេសសិក្សាលើការងារបង្ការមេរោគអេដស៍។
- ចូលរួមជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី ក្នុងកិច្ចពិភាក្សាតុមូលលើប្រធានបទ "ការទាញយកប្រយោជន៍ពីរចនាសម្ព័ន្ធឆ្លើយតបនៃមេរោគអេដស៍ ដើម្បីឆ្លើយនឹងការរើសអើង និងផលប៉ះពាល់សង្គម-សេដ្ឋកិច្ចដែលប្រឈមមុខដោយប្រជាជនគន្លឹះ។
- ចូលរួមកិច្ចប្រជុំតាមវីដេអូនៃគណៈកម្មការសម្របសម្រួលថ្នាក់ប្រទេសសម្រាប់មូលនិធិសកលលើកទី១១ រៀបចំសមាសភាពគណៈកម្មការអាណត្តិថ្មី ២០២១ ដល់២០២៣។

ឯកឧត្តម រស់ សីលវ៉ាត់ (ត)

- ពិភាក្សាការងារជាមួយឯ.ឧ. ទេសរដ្ឋមន្ត្រី និងឯ.ឧ. អនុប្រធាន ទា ផលា ស្តីពីការរៀបចំសមាសភាពនៃគណៈកម្មការសម្របសម្រួលថ្នាក់ប្រទេសសម្រាប់មូលនិធិសកល អាណត្តិថ្មី។
- ប្រជុំជាមួយមន្ត្រីបច្ចេកទេសបន្ទុទស្សនៈវិស័យទៅក្នុងការអនុវត្តផែនការការងារឆ្នាំ២០២១ ក្រោមថវិកាជាតិនិងមូលនិធិសាកល។
- ប្រជុំតាមវីដេអូជាមួយក្រុមការងារ LHSS និងជាមួយគណៈកម្មាធិការ/លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តបាត់ដំបងស្តីពីការសិក្សាស្រាវជ្រាវមូលដ្ឋានស្តីពីសមត្ថភាពបង្កើតនូវយុទ្ធសាស្ត្រសុខាភិបាលដែលមានថវិកានៅថ្នាក់ក្រោមជាតិ។
- ជួបពិភាក្សាការងារជាមួយឯ.ឧ. ទេសរដ្ឋមន្ត្រី និងឯ.ឧ. អនុប្រធានទា ផលា ស្តីពីការបញ្ចប់គម្រោងរបស់អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ BFD នៅបាត់ដំបង។

ឯកឧត្តម រស់ សីលវ៉ាត់ (ត)

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ចូលរួមរៀបចំតាមដានការអនុវត្តការងារ សជណ លេខ២១៣។
- ចូលរួមរៀបចំការងារត្រៀមបញ្ជាបការអនុវត្ត ស.ជ.ណ. ២១៣ ទៅខេត្តផ្សេងៗ។
- ចូលរួមប្រជុំថ្នាក់ដឹកនាំប្រចាំខែវិច្ឆិកា ឆ្នាំ២០២០។
- ការងារផ្សេងៗដែលយោលតាមសភាពការណ៍វិវត្តន៍ចាំបាច់ និងយោលតាមការចាត់តាំងរបស់ឯកឧត្តមប្រធាន។

ឯកឧត្តម ជា ពៅ

- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែតុលា ឆ្នាំ២០២០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- រៀបចំរបាយការណ៍គណៈកម្មាធិការត្រួតពិនិត្យគណបក្សអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០២០។
- ចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជននៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរពវិញ្ញាណក្ខន្ធព្រះករុណា "ព្រះបរមរតនកោដ្ឋ។
- តាមដាន និងផ្សព្វផ្សាយករណីកូវីដ១៩ ក្នុងព្រឹត្តការណ៍៣ថ្ងៃកា ឆ្នាំ២០២០។
- ចូលរួមកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតប្រចាំឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម ជា ដោ (ត)

- ពិនិត្យមើលរបាយការណ៍បច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាន។
- ផុសក្នុងហ្វេសបុកផេកសរុបបានចំនួន១១ដង ក្នុងខែវិច្ឆិកា ឆ្នាំ២០២០។
- បញ្ចប់របាយការណ៍គណៈកម្មាធិការត្រួតពិនិត្យគណបក្សអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០២០។
- បានពិនិត្យគម្រោងផែនការសកម្មភាពប្រចាំឆ្នាំ២០២១របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ក្នុងខែធ្នូ បានផុសក្នុងហ្វេសបុកផេកសរុបចំនួន ១៥ដង។

ឯកឧត្តម ជា ដៅ (ត)

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមចូលរួមការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២០។
- បន្តតាមដានករណីជំងឺ Covid-19 ដើម្បីចូលរួមធ្វើការផ្សព្វផ្សាយ។
- ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រៀមចូលរួមការងារផ្សេងៗ តាមការចាត់តាំងរបស់ឯកឧត្តមប្រធានអ.ជ.ប.ជ.អ។

សំណូមពរ

- ស្នើសុំថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសទាំងអស់ ដែលបានចុះបំពេញការងារ សិក្ខាសាលា កិច្ចប្រជុំផ្សេងៗ ជួយផ្តល់អត្ថបទព័ត៌មានខ្លី ភ្ជាប់ជាមួយរូបភាព ដើម្បីយកមកផុសក្នុង Facebook Page អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តម ហោ ប៊ុនឡេង

- បានពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍របស់អគ្គលេខាធិការដ្ឋាន។
- ចូលរួមអមដំណើរឯកឧត្តមទេសរដ្ឋមន្ត្រី ដើម្បីចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ និងថ្វាយកម្រងផ្កា គោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា "ព្រះបរមរតនកោដ្ឋ"។
- ចូលរួមប្រជុំជាមួយក្រុមការងារក្រសួងកិច្ចការនារីស្តីពីការរៀបចំទិវាភាពជាអ្នកដឹកនាំ ក្រោមប្រធានបទ "សីលធម៌ និងគុណធម៌នៃភាពជាអ្នកដឹកនាំ"។
- ចូលរួមកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតប្រចាំឆ្នាំ២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចូលរួមពិភាក្សាជាមួយក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ ក្នុងការរៀបចំគម្រោងឥស្សរជនឆ្នើមថ្នាក់ជាតិ ដើម្បីចូលរួមទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ។

ឯកឧត្តម ហោ ប៊ុនឡេង (ត)

- ចូលរួមធ្វើបទបង្ហាញ ស្តីពីសីលធម៌ និងគុណធម៌នៃភាពជាអ្នកដឹកនាំនៅក្រសួងកិច្ចការនារី។
- បានចូលរួមការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ តាមរយៈតុមូល នៅកាកបាតក្រហមកម្ពុជា។
- បានពិនិត្យគម្រោងផែនការសកម្មភាពប្រចាំឆ្នាំ២០២១របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសឥស្សរជនឆ្នើមថ្នាក់ជាតិក្នុងការរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ។
- បានរៀបចំការបកប្រែនូវប្រវត្តិនៃការរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍មួយធ្នូដាក់ទៅក្នុងគេហទំព័រអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តម ហោ ប៊ុនឡេង (ត)

- បានចូលរួមកិច្ចប្រជុំរៀបចំសេចក្តីព្រាងរបាយការណ៍ឥស្សរជនឆ្នើមថ្នាក់ជាតិប្រចាំឆ្នាំ២០២០ ជូនទៅអង្គការសហប្រជាជាតិ។
- បានរៀបចំកិច្ចប្រជុំរៀនសូត្រពីគ្នាទៅវិញទៅមកជាមួយឯកឧត្តមអនុប្រធាន ស៊ឹម គឹមសែន ស្តីពីចំណេះដឹង ជំនាញ និងបទបិសោធន៍ នៃភាពជាអ្នកដឹកនាំប្រកបដោយឥទ្ធិពល និងប្រសិទ្ធភាពឆ្ពោះទៅបញ្ចប់ជំងឺអេដស៍នៅកម្ពុជា និងនៅលើសកលលោក។
- បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០២០ ក្រុមការងារទូតសុឆន្ទៈភាពជាអ្នកដឹកនាំ និងលើកទិសដៅឆ្នាំ២០២១ ក្រោមការដឹកនាំរបស់ក្រុមការងារក្រសួងកិច្ចការនារី។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ត្រៀមចូលរួមកិច្ចប្រជុំនានាតាមការចាត់តាំងរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ត្រៀមធ្វើការងារតាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

ឯកឧត្តម ស៊ឹម គឹមសាន

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍របស់អគ្គលេខាធិការដ្ឋាន។
- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែតុលា ឆ្នាំ២០២០ ក្រោមអធិបតីឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចូលរួមអមដំណើរឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ ក្នុងទិវារបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងបន្តទៅដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ។
- ចូលរួមកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតប្រចាំឆ្នាំ២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តម ស៊ឹម គឹមសាន (ត)

- បន្តតាមដានការរៀបចំធ្វើផែនការឆ្លើយតបនឹងការរាលដាលនៃមេរោគអេដស៍ និងជម្ងឺអេដស៍ របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំទាំងអស់របស់ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។
- បន្តរៀបចំផែនការសកម្មភាពផ្សព្វផ្សាយចំណេះដឹងពីអេដស៍ដល់ប្រជាសហគមន៍ និងឧទ្យានុរក្ស នៅបណ្តាខេត្តផ្សេងៗទៀត ជាមួយឯកឧត្តមប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺ អេដស៍ ក្រសួងបរិស្ថាន។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ត្រៀមចូលរួមកិច្ចប្រជុំនានាតាមការចាត់តាំងរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រៀមធ្វើការងារតាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

២. សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន

២. សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន

- កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១១
- កិច្ចប្រជុំប្រចាំសប្តាហ៍ ប្រចាំឆ្នាំ
- រៀបចំរបាយការណ៍កិច្ចប្រជុំពេញអង្គ សន្និបាត និងរបាយការណ៍ប្រចាំឆ្នាំ
- រៀបចំផែនការសកម្មភាព និងថវិកាអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២១
- រៀបចំបញ្ចប់គោលការណ៍ណែនាំស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល
- រៀបចំបញ្ចប់ពាក្យបំព្រួញទាក់ទងនឹងការងារមេរោគអេដស៍ និងជំងឺអេដស៍
- វគ្គបណ្តុះបណ្តាលគម្រោងមូលនិធិសកល
- បិទបញ្ជីចំណាយថវិកាជាតិ ថវិកាមូលនិធិសកលឆ្នាំ២០២០។

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២០

កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស

1. បទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ក្រុមប្រឈមមុខខ្ពស់ ការឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រសម្រាប់ប្រជាជនទូទៅ និងក្រុមប្រឈមមុខខ្ពស់ (RHAC)
2. ការសិក្សាពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើសហគមន៍ អ្នកផ្តែកមេរោគអេដស៍ វឌ្ឍនភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ប្រជាជនគន្លឹះ(UNAIDS)
3. បច្ចុប្បន្នភាពនៃអន្តរាគមន៍បង្ការមេរោគអេដស៍លើក្រុមប្រឈម ភាពជោគជ័យ ការប្រឈម មេរៀនជាបទពិសោធន៍ និងទិសដៅរបស់អង្គការ (KHANA)
4. ប្រធានបទ ស្ថានភាពទូទៅនៃប្រជាជនប្រឈម ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទនៅកម្ពុជា (RHAC)
5. ការអនុវត្តជាក់ស្តែងរបស់អង្គការCRS ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ (CRS)
6. ការអភិវឌ្ឍជំនាញក្នុងការបញ្ចូលសកម្មភាពឆ្លើយតបមេរោគអេដស៍ក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ (CRS)
7. ប្រធានបទ ស្ថានភាពប្រឈមនៃមេរោគអេដស៍អេដស៍ និងជំងឺអេដស៍នាពេលបច្ចុប្បន្នក្នុងចំណោមបុរសរួមភេទជាមួយបុរស និងក្រុមស្រីស្រស់ (FHI 360 & KHANA)

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២០

8. ការលេបថ្នាំបង្ការជាមុន (PrEP) នៅពេលប្រព្រឹត្តប្រឈមនឹង ការឆ្លងមេរោគអេដស៍ (NCHADS &FHI360)
9. ប្រធានបទ និយាមប្រតិបត្តិស្តីពីវិធីធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង(Standard of procedure on HIV/AIDS Self Testing) (FHI 360)
10. បទបង្ហាញពីនីតិវិធីអត្តសញ្ញាណគ្រួសារក្រីក្រ សម្រាប់អ្នកផ្ទុកមេរោគអេដស៍ (MOP)។

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២០

ឥតគ្គបណ្តុះបណ្តាល

- នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បង្ហាញដោយ លោក សរ ជីវ័ន្ត អនុប្រធាននាយកដ្ឋាន និងមន្ត្រី០២ រូបនៃនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ។
- អំពីសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គម ឃុំ សង្កាត់ បង្ហាញដោយ លោក ម៊ុន ស៊ីថា អនុប្រធាននាយកដ្ឋានគ្រប់គ្រងកិច្ចការរដ្ឋបាល ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ និងមន្ត្រីជំនាញមកពីអង្គការ UNICEF។
- CamBlitz: Patient Dossier Review among ART Cohort(Mr. Chanry, FHI 360)
- ស្វែងយល់អំពីការរាតត្បាតនៃជំងឺកូវីដ១៩ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ធ្វើបទបង្ហាញដោយ ឯកឧត្តមវេជ្ជ. ហោ ប៊ុនឡេង។
- ការធ្វើផែនការយុទ្ធសាស្ត្រ ឧទ្ទេសដោយ ឯកឧត្តមវេជ្ជ. ហោ ប៊ុនឡេង។
- បុរសរួមភេទជាមួយបុរស ឧទ្ទេសដោយ ឯកឧត្តមវេជ្ជ. តែង គន្ធី ។

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២០

- សារលិខិត សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០២០
- ទិន្នន័យសង្ខេបឆ្នាំ២០១៩ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា
- គោលការណ៍ណែនាំស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល
- ពាក្យបំព្រួញទាក់ទងនឹងការងារមេរោគអេដស៍ និងជំងឺអេដស៍
- ផែនការសកម្មភាព និងចក្ខុវិការអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២១



សារលិខិត
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០២០



ទិន្នន័យសង្ខេបឆ្នាំ២០១៩ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា

I. ស្ថានភាពបច្ចុប្បន្ននៃមេរោគអេដស៍ និងជំងឺអេដស៍ នៅប្រទេសកម្ពុជា ឆ្នាំ២០១៩

II. អត្រាប្រាំមួយនៃក្រុមប្រជាជនគន្លឹះ

ក្រុម	អត្រាប្រាំមួយនៃជំងឺអេដស៍	ប្រភព
ស្ត្រីបម្រើកំសាន្តសប្បាយ	៣,២%	IBBS ២០១៦
អ្នកប្រើប្រាស់គ្រឿងញៀន	៥,៣%	IBBS ២០១៧
អ្នកបាក់គ្រឿងញៀន	១៥,២%	IBBS ២០១៧
បុរសរួមភេទជាមួយបុរស	៤,០%	IBBS ២០១៩
ក្រុមប៉ារ៉ែងភេទ	៩,៦%	IBBS ២០១៩

ក្រុម	អត្រាប្រាំមួយនៃជំងឺការមានផ្ទៃពោះ	ប្រភព
ស្ត្រីបម្រើកំសាន្តសប្បាយ	១៩%	IBBS ២០១៦
អ្នកប្រើប្រាស់គ្រឿងញៀន	៣,៤%	IBBS ២០១៧
អ្នកបាក់គ្រឿងញៀន	៥,២%	IBBS ២០១៧
បុរសរួមភេទជាមួយបុរស	១៨,៥%	IBBS ២០១៩
ក្រុមប៉ារ៉ែងភេទ	២៥,៥%	IBBS ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

គោលការណ៍ណែនាំ
ស្តីពី
ការបង្ការការចម្លងមេរោគអេដស៍ជាសកល

ខែធ្នូ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យបំព្រួញទាក់ទងនឹង
ការងារមេរោគអេដស៍ និងជំងឺអេដស៍

ខែធ្នូ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គម្រោងផែនការសកម្មភាព និងចក្ខុវិការ
អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
ឆ្នាំ២០២១

ខែធ្នូ ឆ្នាំ២០២០

ផែនការសកម្មភាព និងឋវិការអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ឆ្នាំ២០២១

ផ្អែកលើ ឯកសារសំខាន់ៗ៖

- សមិទ្ធផលដែលសម្រេចបាន និងឧបសគ្គដែលកើតមានឡើងក្នុងការអនុវត្តផែនការសកម្មភាពឆ្នាំ២០២០ ហើយដែលត្រូវដាក់សកម្មភាពអនុវត្តសម្រាប់ឆ្នាំ២០២១។
- សកម្មភាពអាទិភាពដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី៥ នៃការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ២០១៩-២០២៣។
- សកម្មភាពដែលត្រូវបន្តអនុវត្ត ស.ជ.ណ ២១៣
- សកម្មភាពសម្រាប់អនុវត្តអនុសាសន៍១០ចំណុចរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ដែលបានសម្រេចក្នុងកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២០។
- សកម្មភាពសម្រាប់ការអនុវត្ត Fast track Cities។
- សកម្មភាពដែលបានកំណត់ក្នុងគម្រោងមូលនិធិសកល ឆ្នាំ២០២១-២០២៣។

ផែនការសកម្មភាព និងថវិកាអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ឆ្នាំ២០២១

វិធីសាស្ត្រ៖

- កិច្ចប្រជុំបច្ចេកទេសអគ្គលេខាធិការដ្ឋានចំនួន ៤លើក
- ស្នើសុំយោបល់ ឯកឧត្តម លោកជំទាវ អនុប្រធាន អ.ជ.ប.ជ.អ និងទទួលបានយោបល់ត្រឡប់៖
  ១. ឯកឧត្តម **គង់ រដ្ឋា**
  ២. ឯកឧត្តម **ទា ផលា**
  ៣. លោកជំទាវ **ស៊ឹម ខេងខាំ**
  ៤. ឯកឧត្តម **ស៊ឹម គឹមសែន**
  ៥. ឯកឧត្តម **តែង គន្ធី**
  ៦. ឯកឧត្តម **រស់ សីលវ៉ាត់**
  ៧. ឯកឧត្តម **ជា ប៉ោ**
  ៨. ឯកឧត្តម **ហោ ប៊ុនឡេង**
- គោរពសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី** ដើម្បីដាក់អនុវត្តជាផ្លូវការ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០២១ តទៅ។

ផែនការសកម្មភាព និងថវិកាអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ឆ្នាំ២០២១

✓ យុទ្ធសាស្ត្រៈ ៤ (NSP V)

ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យស្តីយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ (២០១៩-២០២៣) ដែលមានចក្ខុវិស័យ ***"កម្ពុជាគ្មានមេរោគអេដស៍ ប្រជាជនទាំងអស់មានសុខភាពល្អប្រសើរ និងមានសុខមាលភាព"*** *និងមានគោលបំណងឆ្ពោះទៅបញ្ចប់អេដស៍ ដែលជាការគំរាមដល់សុខភាពសាធារណៈនាឆ្នាំ២០២៥។*

✓ កម្មវត្ថុៈ ៩

✓ សកម្មភាពៈ ៧៦

✓ តម្រូវការថវិកាសរុបចំនួន **5,556,200,000រៀល** និង **84,371ដុល្លារអាមេរិក**

បញ្ហាប្រឈម

- ស្ថានភាពជំងឺកូវីដ១៩ នៅតែបន្តផលប៉ះពាល់ការអនុវត្តសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- ថវិកាជាតិកាត់បន្ថយលើសកម្មភាពជាអាទិភាពរបស់ អ.ជ.ប.ជ.អ: បេសកកម្ម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល ការផ្សាព្វផ្សាយ
- នីតិវិធីចំណាយថ្មី ធ្វើឱ្យមានការប៉ះពាល់លើដកថវិកាយកមកអនុវត្ត ដូចជា ជុំវដ្តទេយ្យមានកម្រិតទឹកប្រាក់តិច
- មិនទាន់មានការបញ្ជាក់លើនីតិវិធី ចំណាយសោហ៊ុយបេសកកម្មក្នុងប្រទេស និងកិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល
- ថវិកានៃគម្រោងមូលនិធិ (២០២១-២០២៣) មិនទាន់កំណត់ច្បាស់លើការដកមកប្រើប្រាស់បាននៅឡើយ

ជំហានបន្ទាប់

- អនុវត្តផែនការសកម្មភាព និងថវិកាអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២១
- ពិនិត្យ តាមដាន វាយតម្លៃការអនុវត្តផែនការសកម្មភាព និងត្រៀមនូវការកែសម្រួលសកម្មភាពដើម្បីសម្រេចគោលដៅដែលបានកំណត់
- ពង្រឹងសមត្ថភាពទាំងផ្នែកការដឹកនាំ និងបច្ចេកទេស
- សិក្សាកាលានុវត្តភាពផ្សេងៗ ដែលអាចជួយសម្រេចគោលដៅ និងសកម្មភាពដែលកំណត់។

សូមអរគុណ!